Khmer Story Lovers

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ១៤

ស៊ីឈិនដកដង្ហើមធំ:

—ហ៊ី ! បងប្អូនខាងភ្នំទឹកកក រាប់អានស្រឡាញ់កូនប្រុសខ្ញុំណាស់, តែអាកូនខ្ញុំជាក្មេងចិលខូចដូរជាតិក្រៃលែង ធ្វើឲ្យលោកអ៊ំប៉ាយនិងលោកបងហុង ខកចិត្តអស់រលីង ។ ប្ដីប្រពន្ធខ្ញុំឮដំណឹងនេះ ត្រេកអរផង អៀនខ្មាសផង មិនគួរមានកូនបែបហ្នឹងសោះ ! ឥឡូវលោកអ៊ំប៉ាយសុខសប្បាយទេ ! លោកអ៊ំស្រីយ៉ាងម៉េចដែរ ?

ពោលផងប្ដីប្រពន្ធនាំគ្នាលំឱនកាយគោរពម្ដងទៀត ដើម្បីសួរសុខទុក្ខចាស់ទុំ ។ ប៉ាយវ៉ាន់ជាន លំឱនកាយគោរពតបវិញ :

—លោកពុកសុខជាទេ, ប៉ុន្តែម្ដាយខ្ញុំនោះ ហ៊ី !... ដោយសាររឿងកូនប្រុសលោក គាត់បានចាកចេញពីភ្នំទឹកកកបាត់ហើយ ។

ប៉ាយវ៉ាន់ជានពោលទាំងមុខស្រងូត, ស៊ីឈិនតបថា :

—លោកអ៊ំស្រីមានយុទ្ធសិល្បៈខ្ពង់ខ្ពស់ ព្រមទាំងកេរ្តិ៍ឈ្មោះល្បីល្បាញ ហើយធ្លាប់តែប្រព្រឹត្តអំពើល្អ, បានចុះពីភ្នំកំសាន្តកាយក្នុងពិភពគុនម្ដងប្រហែលមានសុខភាពល្អណាស់ ។ ខ្ញុំឮអ្នកក្លាហានសរសើរគាត់គ្រប់មាត់ ។

ប៉ាយវ៉ាន់ជានឆ្លើយ :

– សូមអរគុណលោកណាស់ដែលបានជូនពរដល់ម្ដាយខ្ញុំ , តែខ្ញុំជាកូនព្រួយបារម្ភពន់ពេក ដោយហេតុម្ដាយចាស់ជរាហើយ ។

– លោកបងប៉ាយមានប្រសាសន៍ត្រូវ ។ យើងជាកូនគោរពមានកតញ្ញូតាធម៌ចំពោះអ្នកមានគុណ, រីឪពុកម្ដាយវិញក៏តែងព្រួយបារម្ភ ចំពោះកូនប្រុសស្រីដែរព្រោះនេះជាការធម្មតាសំរាប់សត្វលោករួចទៅ ។ ម្យ៉ាងទៀតពេលបើកូននោះប្រព្រឹត្តខុសឆ្គងយ៉ាងណាក៏ម្ដាយឪពុកត្រូវនាំ ទៅប្រថែប្រដៅឲ្យអស់ចិត្តដែរ ។

ប៉ាយវ៉ាន់ជានប្រហមគុម្ពត្របៀកឆ្លើយតបវិញថា :

– លោកម្ចាស់ភូមិត្រកូលស៊ីជាអ្នកក្លាហានមួយរូប ដែលអ្នកគុននិយមខ្លួនទៅគោរពផងខ្លះ ។ ខ្ញុំនៅចាំបានថា មាត់ច្រកភូមិលោកមានក្ដារមួយបន្ទះសរសេរអក្សរថា «យុត្តិធម៌ឥតប្រែប្រួល» មែនទេ ?

ដូចជា មែន ! ឥឡូវបន្ទះក្ដារទៅណាហើយ ?

ហា ប៉ាយវ៉ាន់ជានស្រឡាំងកាំង រួចឆ្លើយតាមត្រង់ :

- ក្ដារនោះខ្ញុំដុតចោលបាត់ហើយ ។

–ប្រសើរណាស់លោក ! កូនខ្ញុំជាសិស្សក្មួយកតក បើវាប្រព្រឹត្តអ្វីខុសច្បាប់នឹងក្រុមលោក លោកត្រូវវិនិច្ឆ័យទោសវាជាដាច់ខាត ! ខ្ញុំជាម្ដាយឪពុកឥតមានសិទ្ធិជ្រៀតជ្រែកទេ នេះជាច្បាប់ទម្លាប់ពិតពិតដែលយើងត្រូវដឹងគ្រប់គ្នា ។ ប៉ុន្តែថ្ងៃមុននៅភូមិហូរជានប្ដីប្រពន្ធខ្ញុំបានប្រគល់ដាវខ្មៅមួយសម្រាប់ជូនក្រុមក្មេងកតកបញ្ចាំចិត្តសិនចាំវាកូនខ្ញុំឃើញ ខ្ញុំនាំវាទៅកាន់ទីតាំងអស់លោក ប្ដូរយកដាវមកវិញ ។ រឿងនេះលោកបងជ្រាបដែរ ?

ប៉ាយវ៉ាន់ជានដឹងរឿងនេះហួតដល់គេដណ្ដើមដាវសងនិងខ្មៅកណ្ដាលផ្លូវបាត់ផង ។ កាលបើឮស៊ីឈីងរំឭករឿងនេះគាត់ក្រហមមុខបន្តិចឆ្លើយតបថា :

– បាទដឹង ! ប៉ុន្តែដាវលោកប្រុសលោកស្រីឥតនៅទីនេះទេ, ចាំថ្ងៃក្រោយខ្ញុំយកទៅជូនលោក ។ សូមអភ័យទោស ។

ស៊ីឈីងសើចហាស ៗ :

- លោកបងម៉ាយមានប្រសាសន៍ដូចជាច្រឡំបន្តិចហើយ ដូចជាមើលងាយរូបខ្ញុំណាស់ ។ ចាប់កូនខ្ញុំហើយយកជាវត្ថុប្រពន្ធខ្ញុំទៀត ! អំពើនេះត្រឹមត្រូវតាមច្បាប់ពិតពុនដែរ?

- ចុះលោកម្ចាស់មានយោបល់បែបណាដែរ ? សុំជួយប្រាប់យើងខ្ញុំផង ។

- សំដីកូនប្រុសមួយម៉ាត់ៗមានតម្លៃណាស់ ៖ បើចង់បានកូនខ្ញុំធ្វើទោសមិនត្រូវទទួលជាខ្ញុំទៀតទេ, ហើយបើយកជាត្រូវទុកកូនឲ្យខ្ញុំវិញ ។

ម៉ាយរ៉ាន់ជានធ្លាប់អង់អាចក្លាហាន, តែពេលនេះគាត់ខ្លាចស៊ីឈីងណាស់ព្រោះកូនប្រុសគេនៅនឹងខ្លួនមែន ប៉ុន្តែរក្សាជាវគេមិនគន់ ។ តាមពិតគាត់មិនត្រូវដែលវែកញែកគេឈ្មោះបាញ់ជាមួយស៊ីឈីងទេ តែគាត់បានពិគ្រោះជាមួយទិនរ៉ាន់ផុងជាប្រាំហៅលស៊ីឈីងផ្សំគំនិតជាមួយសៃយានទីឲ្យស្កាត់ដណ្ដើមជាវពីក្រុមក្លូទិកកកទេផង?

ពោះបើយ៉ាងនេះក្ដីស៊ីផុងយីធ្វើឲ្យគាត់បាត់កូនស្រីពន្ធកមួយ គាត់ត្រូវតែចាប់វាទៅកាន់ក្លូទិកកក មិនត្រូវការឲ្យអ្នកក្រៅប៉ះពាល់ទេ ។ កាលបើបានពិចារណាដូច្នេះគាត់ទាំមាត់តបថា៖

-រឿងនេះខ្ញុំសម្រេចមិនបានទេសូមលោកម្ចាស់អភ័យទោស ។ រឿងជាវទាំងពរខ្ញុំវាយកមកប្រគល់ជូនលោកជាដាច់ខាត, បើមិនបានដូចពាក្យសន្យាខ្ញុំនឹងធ្វើអត្តឃាតនៅចំពោះមុខលោកតែម្ដង ។

ពាក្យសំដីអស់នេះត្រូវគាត់ពោលចេញមក យ៉ាងដាច់ណាត់, ស៊ីឈីងយល់ភ្លាមថាម៉ាយរ៉ាន់ជានមានឋានៈខ្ពស់តែងតែគោរពពាក្យសច្ចៈម្ល៉ោះហើយគាត់ត្រូវតែជឿថាអ្នកក្លាហានទិសវត្តពិតជាប្ដូរជីវិតដើម្បីសច្ចៈនឹងមែន ។ តែម្ចាស់ភូមិឋានសាំងស៊ូក៏មិនអាចបណ្ដោយឲ្យកូនប្រុសធ្លាក់ក្នុងកណ្ដាប់ដៃគេយ៉ាងងាយដែរ ។ អ្នកស្រីវ៉ុនឃូតាំងពីចូលដល់រោងកញ្ចាស់នេះគាត់សម្ងំស៊ីផងានឥតដាក់ភ្នែកចង់ស្ទុះទៅបបោសអង្អែលថ្នាក់ថ្នមតាមចិត្តម្ដាយនឹករឭកកូនដែលបែកព្រាត់គ្នាយូរឆ្នាំ ។ គាត់ឈរសម្ងំមាឃោពស្រក់ទឹកភ្នែករហាម ស្ទើរទ្រហោយំឥតរវល់ស្ដាប់ម៉ាយរ៉ាន់ជានឡើយព្រោះគាត់ខ្លួចចិត្តថ្ពីណាស់ ។

ស៊ីឈីងពោលទៀតថា៖

- លោកម៉ាយកុំមានប្រសាសន៍ធ្ងន់ពេក ។ ជាតិមួយគួតមានតម្លៃស្មើជីវិតលោកទេ អ្នកខ្ញុំតែចង់និយាយការពិត ជូនលោកបងវ៉ៃតែរៀងអង្គ ព្រោះយើងជាអ្នកគុនឧិយមដូចគ្នា ។

ក្រុមភ្នំទឹកកកមានគ្នាច្រើនហើយចេះតែនាំគ្នាកៀកចំណាប់មិនគួរ...លាភគេដោយ ចាប់តាំងពីកូនយកតាំងជា
ទៀយ ។ លោកបងប៉ាយ ! ថ្ងៃនេះខ្ញុំបបួលភរិយាមកនាំកូនត្រឡប់ទៅផ្ទះសម្បែងវិញហើយ

ពេលតែប៉ុណ្ណេះគាត់គ្រវែងខ្លួនឡើងសញ្ញាទៅវ៉ុនយូហូតអាវុធវាយលុកភ្លាម ។ គេឃើញ
តែពន្លឺដាវភ្លឺចែកភ្លេត ហើយអ្នកស្រីវ៉ុនយូអាវុធចុចដាវពារលើទ្រូងប៉ាយកាន់ជានដំណាលស្មាម
ចុងដាវតាំងពីរហៀបចេះដើមទ្រូងប៉ាយកាន់ជានទៅហើយ ស្រាប់តែគេឈប់នឹកដំណាលគ្នា។ ស៊ីណើ
ស្រែកថា :

– សូមលោកបងប៉ាយអញ្ជើញ !

នេះជាកាយវិការត្រឹមត្រូវថ្លៃថ្នូរនៃប្ដីប្រពន្ធស៊ីណើងដែលប៉ុះពោលប៉ាយកាន់ជានហូតអាវុធមកចប់ល់
បើប៉ាយកាន់ជានមិនដកដាវមកទេ ពីនាក់គេក៏មិនរុញដាវចាក់ថែមដែរ ។

## ខគ្គទី ១៤

## ឥតចិត្តស្តាយ

ប៉ាយកាន់ជានសម្លឹងដាវតាំងពីរបោះជំហានទៅមុខបន្តិច , ស៊ីណើងនិងវ៉ុនយូក៏ហក់ថយមួយជំហា
ដែរ ។ ប៉ាយកាន់ជានហក់ថយក្រោយវិញភ្លាមឮតែង ! គឺគាត់បានហូតអាវុធយ៉ាំងរហ័
មកកាត់រងដាវមួយគូនៃម្ចាស់ភូមិបានសាំនស៊ីស្រេច ។ អាវុធតាំងបីវិលកាត់រកគ្នាដូចចុងព្រួញត្រូវខ្យ
កួចកណ្ដាលវាលល្ហល្ហេវ ។ សិស្សភ្នំទឹកកកតាំងអស់ចាប់កោតស្ញប់ស្ញែងយុទ្ធសិល្ប៍បងវ៉ូមត្រូវ
-ដើមមក , គេផ្ទុកញញើតសោះឡើយ នឹកថាៈភារៈប្ដីប្រពន្ធស៊ីណើងត្រូវគ្នា ក៏មិនឈ្នះបងវ៉ូមប្រ
នៅដែរ, ឡោះហើយម្នាក់ ៗ ឈរទេចដៃមើលធ្វើព្រងើយ ។

មុនដំបូងស៊ីណើងនិងវ៉ុនយូវាយយឺតាវកាច.មើលស្នៀតមួយៗច្បាស់បន្តិច ។ ក្នុងប្រហែ
សាមសិបស្នៀតប្ដីប្រពន្ធមួយគូនេះបញ្ចេញកាយវិការញាប់រន្ធើនឃើញតែពន្លឺសព្រោក ។ ប៉ាយ
កាន់ជានដៃបេញ្ចាប់ហាត់គុនដាវប្រចាំក្រុមភ្នំទឹកកកតាំងចិតសិបពីរស្នៀតជារៀងរាល់ថ្ងៃ គាត់ស្មាន
យុទ្ធសិល្បៈប្រចាំក្រុមមានសភាពធម្មតាណាស់ ដល់ពេលវាយលុកឬរងកាត់ទើបគាត់ដឹងថាយុ
សិល្បៈភ្នំទឹកកកមានប្រសិទ្ធភាពណាស់ទៅវិញ !

ក្នុងខ្ទមតាំងមូលមានតែទៀនមួយដុតបំភ្លឺ តែគេចាំងភ្នែកដោយសារពន្លឺអាវុធតាំងបីវែកផ្កាភ្លើងម្ល

ក្ដិចញ្ចាច ម្ដងក្ដិបក្រែតដូចផ្គរបង្គោរតួរស៊ើប ។ ផ្ទុំមុខយុទ្ធជនទាំងបីរួចក៏ផ្លាស់ពីទីនឹងទៅក្ដីដៃរ ដាវនីមួយៗវាយវ៉ាត់កាលណា គេចំដកដង្ហើមវង់ហាំមើលលទ្ធផលជានិច្ច ។ ប៉ុន្តែអ្នកទាំងបីនៅមានជំហររឹងប៉ុងដដែល គឺប៉ុយវ៉ាន់ជានធ្វើមុខហាំ, ស៊ុំឈើងរៀបចិត្តមុខស្មើ និង វុនយូស្រងូតស្រងាត់ ។

និយាយពីស៊ុំផានវិញ នាយស្គាល់ស៊ុំឈើង និងវុនយូ តាំងពីប្ដីប្រពន្ធនេះចូលដល់កោងកញ្ចាស់ក្វាមម៉ោះ ។ តែ្បិតកាលនៅគួបហ្វូវជាន អ្នកស្រីពាក់អាវៈបានឲ្យលុយនាយទិញនំសុំ ។ ប៉ុន្តែនាយរកពេលនិយាយរក ឬ សាកសួរអ្នកទាំងពីរមិនបាន ព្រោះគេរវល់ធ្វើដំណើរជាមួយប៉ុយវ៉ាន់ជាន ហើយបើកធាក្រប្រយុទ្ធរហូតមក ។ ចំពោះការសន្ទនាមួយចប់នេះ មាណពស្ដាប់ឮផកបន្ទោះមួយម៉ាត់សោះឡើយ តែនាយមិនយល់ទាំងអស់ទេ គ្រាន់តែដឹងថាស៊ុំឈើងតាវដាវមួយគូ ពីប៉ុយវ៉ាន់ជាន ព្រមទាំងកូនប្រុសមួយរូបទៀត ។ អស្ចារ្យបំផុតត្រង់នាយផកដឹងថាប្ដីប្រពន្ធនេះចង់ផ្ដើមរូបនាយពីគ្រុបក្ដីទឹកកកវេ ។

អម្បាញ់មិញនាយសម្លឹងមើលសិស្សខាងក្ដីទឹកកក ទាំងឧបពីរនាក់ប្រឡងសាកថ្វីដៃគ្នាដោយឥតដាវដែកឡូឡា, ហើយពេលនេះឃើញបីនាក់ដកដាវស៊ុំសងគ្នាទៀត នាយយល់ថាគេសាកល្បង «លេង» ដដែល ព្រោះទឹកមុខអ្នកទាំងបីឥតប្រែប្រួលឥតបញ្ចេញអាកប្បកិរិយាខ្លាំងក្លា ព្រមទាំងឥតពោលពាក្យដេរត្មះតិះដៀលគ្នាផង ។ ចំពោះយុទ្ធសិល្ប គុនដាវរបស់សិស្សក្ដីទឹកកកទាំងចិតសិបពីរស្នៀតនាយមើលចប់យល់អស់ស្រេចហើយ ។ ប្ដូងនេះឃើញប៉ុយវ៉ាន់ជានសំដែងម្ដងទៀតនាយរឹតតែយល់ច្បាស់លាស់ឥតបាច់មានគ្រូអធិប្បាយ ។

លុះចេះចប់ហើយមាណពវៃរមើលស្នៀតគុនដាវរបស់ស៊ុំឈើងនិងវុនយូម្ដង ។ អ្នកកះម្ពាះយល់ក្វាមថាស្នៀតដាវស៊ុំឈើងយើតៗតែពត់មួយបានមួយ ។ ដាវអ្នកស្រីស្នៀតពាក់សស្រាលៈហើយហ៍សក្ដិបក្រែតសមដំណើរស្ត្រីវែ។ រួមគ្នាប្រយុទ្ធនឹងប៉ុយវ៉ាន់ជាន កាវុងទាំងពីររួមបញ្ចូលគ្នាដូចដាវតែមួយម្ដងដូចមនុស្សតែម្នាក់ ។ ការពិតដូច្នេះមែនព្រោះប្ដីប្រពន្ធស៊ុំឈើងបានគប់ប្រសព្វគ្នាជាងវៃម្ភៃឆ្នាំហើយ គាត់មិនដែលបែកឃ្លាតគ្នាមួយថ្ងៃឡើយ ។

ប្ដីប្រពន្ធតែងខំហាត់ហ្វឹកហ្វឺនយុទ្ធសិល្បៈ រៀនរាល់ពេលពេញយល់ចិត្តគ្នា, យល់បំណងគ្នាៈដោយឯងៗ ។ គុនដាវល្អប្រណីតរបស់ពីរនាក់ប្ដីប្រពន្ធនេះល្បីល្បាញក្នុងពិភពគុនទាំងមូលបែងភពោក

អ្នកក្លាហានណាប្រដូចបានឡើយ ។ ទ្រឹស្តីអស់នេះជ្រៅជ្រះណាស់, ស៊ីផានមើលមិនយល់ទាំងអស់ទេ ។ លុះពិនិត្យយូរនាយក្បាក់ព្រើតហាក់ដូចនឹកឃើញអ្វីមួយ ។

ក្បួនមាណពរបេះយុទ្ធសិល្បៈតាមរបៀបប្លែកអស្ចារ្យមុនដំបូងហាត់ធាតុត្រជាក់ បន្ទាប់មកហាត់ធាតុក្តៅតាមវិសិយានទី, ក្រោយបំផុតហាត់យុទ្ធសិល្បៈបង្ក្រាបបិសាចតាមរូបគត្ថា ។ កម្លាំងធាតុគ្រប់ជំពូក នេះបានមូលផ្តុំគ្នាក្នុងរូបកាយនាយហើយ ពាស់ត្រង់មិនទាន់បេះប្រើប៉ុណ្ណោះ ។

ឥឡូវនាយទទួលអារម្មណ៍ចំឡែកដូចដែលស្គាល់ថាដែលហាត់ស្នៀតដាវអស់នេះដែរ ។ នាយឆ្ងល់ណាស់ផ្តើនសួរថា: យើងហាត់គុនដាវពីពេលណាហ្ន៎?

ឡើតស៊ីឈីង ឬ វ៉ុនយូលើកការុន មាណពមើលយល់មុនថា គេចង់ធ្វើបែបណាទៅហើយប្រៀបដូចគ្រូបាធ្យាយ សម្លឹងមើលសិស្សបង្ហាញយុទ្ធសិល្បៈ ដើម្បីពន្យល់ថែមអំពីចំណុចណាមួយដែលមិនសូវត្រូវ ឬ មិនសូវយល់ ។

វេលានោះមាណពក្រាក់ក្រញាង ដឹកខ្លួនចាប់ផ្តើម ស្នៀតគុនដាវដំរហ័សរហួនរបស់អ្នកទាំងពីរដែរកំតាំងរកចាប់សល់នៅមិនសុខក្បាម ។ មិនយូរប៉ុន្មានមានសាចប៉ាន់ស្មានថា ប៉ាយវ៉ាន់ជានទប់ទល់នឹងប្តីប្រពន្ធស៊ីឈីងមិនបានទៀតផង ។

ក្បួនអ្នកទាំងពីរបេះគុនដាវប្រហាក់ប្រហែលគ្នា អាចចាត់ទុកជាប្រយុទ្ធមួយទល់នឹងមួយបាន ។ ប៉ុន្តែស្រីវ៉ុនយូមិនរវល់ពិនិត្យស៊ីផាន ហើយព្យាយាមបញ្ចេញទេពកោសល្យអស់ពីខ្លួន ម៉្លេះសមប៉ាយវ៉ាន់ជានទប់ទល់មិនបានដល់ពេលនេះទេ ។ ក្នុងចំនួនស្នៀតទេះវ៉ុនយូចាក់សិស្សប្រុងខាងទឹកកកវិះត្រូវពីរបីដង ក៏យបែកញើសទៅហើយ តែគាត់ប្រកាន់ចិត្តក្លាហាន មិនព្រមចុះចាញ់ប៉ុណ្ណោះឯង ។

ខណៈដែលប៉ាយវ៉ាន់ជានចង់ទន់ដៃសិស្សម្នាក់យល់ការស្រែកខ្លាំងៗ :

- មិនបេះខ្មាសគេទេ ពីរនាក់ព្រួតគ្នាវាយម្នាក់! អីលោកស៊ី! បើចិត្តកូនម៉ែសុំប្រយុទ្ធមួយទល់នឹងមួយម្តងសិនកុំប្រួតគ្នាទៀត ប្រយ័ត្នពួកខ្ញុំទ្រាំមិនបាន!

ស៊ីឈីងញញឹម:

- លោកបងនាគភ្លើងហ្វុងវ៉ានល័រនៅទីនេះដែរ? បើមានគាត់នៅក្នុងចំណោមនេះ ម្ល៉េះអញ្ជើញរួមកម្លាំងជាមួយលោកប៉ាយឲ្យឃើញសាឡៅទៅ!

វេលានេះមានន័យថាបណ្ដា ស្បែកមុខកកកាំងអស់ស៊ីឈីនមើលឃើញតែហ្វុនរាត់លើម្នាក់គត់ ដែល អាចរួមកម្លាំងជាមួយប៉ាយកាន់ដាន ។ ស៊ីឈីនយល់ណាស់ដឹងណាស់ថា ការប្រុងប្រ វាយប្រហារមនុស្សម្នាក់បែបនេះទុ ក្រប់ , តែគាត់យល់ម៉្យាងទៀតថា បើគេចាប់កូនប្រុសសម្លាញ់ ទៅដល់ក្នុងមុខកក គាត់គ្មានសង្ឃឹមបានឃើញមុខកូនទៀតទេ ។ ឱកាសមានតែមួយគត់ដើម្បី ជួយស្រោចស្រង់កូនប្រុស ទេ ហើយគាត់មិនអាចគេចគេះតិះដៀលឡើយ ។ គិតម៉្យាងទៀតឃើញ ថាសិស្សក្នុងមុខកកច្រើនហួស ដប់នា ក់ពេកក្លាស់នេះមិនអាចមានប្រៀបលើប្ដីប្រពន្ធគាត់បានដែរ ។

ប៉ាយកាន់ដានឮស៊ីឈីនរំពឹក ភរិយាគភ្ញើងគាត់ទឹងក្រេវនឹកថា:

- ដោយសារតែកូនចង្រៃ ដស៊ីផុនយ៉ាននោះហើយបានជាលោកបងហ្វុនដាច់ដៃម្ខាង . ពេល នេះ ឯងហានរំពឹកឈ្មោះគាត់កំដោរយើងទៀតឬ ?

ប៉ាយកាន់ដានអាល័យតែបែកអារម្មណ៍នឹកដល់បងរួមគ្រូស្រាប់តែស៊ីឈីនចំរើនកំឡាំង ទៀតកៀស ដាវគាត់ទៅម្ខាងវិញ ! អ្នកស្រីវុនយូមិនបង្អែបង្អង់រុញចុងដាវគាត់ ចង្អុលទ្រូងប៉ាយកាន់ដានភ្លាម សិស្សក្នុងមុខកកមិនទាន់ចុះចាញ់សុខចិត្តបង្វែកក្បាលតាមចូកជក្រោះដៀផាក់ជាប្ដីប្រពន្ធស៊ីឈីន លែងប្រណ ហើយ ។

ប៉ុន្តែគាត់ស្មានខុសស្រឡះ ។ វុនយូរុញដាវប៉ះសាច់ទ្រូងគាត់កាលណាក៏ដកចេញវិញ បង្ហូលស្វាមីសិកអាវុធខុកក្នុងស្រោមភ្លាមហើយថយក្រោយជាប្រញាប់ឥតចេញស្តី ។

ប៉ាយកាន់ដានភ្ញាក់មុខបើកភ្នែកវិញនឹកថា :

- ប្ដីប្រពន្ធស៊ីឈីនមានចំណងចង់នាំកូនគេទៅវិញជាក់ស្ដែងណាស់, យើងឃាត់ឃាំងគេ មិនបានដែរ បើគេលើកលែងឲ្យប៉ុណ្ណឹងហើយ ។ ប្រសិនចូលប្រយុទ្ធម្ដងទៀត យើងគ្មាន សង្ឃឹមឈ្នះឡើយទេ ។ ហ៊ឺ ! កូនស្រីបណ្ដូលចិត្តត្រូវសិស្សចង្រៃ ធ្វើបាបទាល់តែបាត់បង់ជីវិត យើងកាត់ចិត្តចុះចាកក្នុងបបួលបងប្អូនស្វែងរកអាក្មេងអប្រិយ ឃើញហើយចាប់បានហើយ មិនសមឲ្យ របូតពីដៃវិញនៅគ្រានេះសោះ! ប្អូនប្រាំពីរនាក់ទៀតជាប់ឃុំក្នុងដំរេគ, ជាវទាំងពីររបូតពីដៃក្រុ ក្នុងមុខកក ! យុទ្ធសិល្បៈផ្នែកគុនដាវដែលស្មានថា ល្បីល្បាញផុតគេក៏អាប់រស្មីបាត់ល្បីឈ្មោះក្នុ គ្រានេះទៀត ! ហ៊ឺ ! .....

ប៉ាយកាន់ដាននឹកអស់សង្ឃឹមគ្រប់បែបយ៉ាងឈរធ្មឹងមួយកន្លែងឥតចេញស្តី ។

ខណៈនោះ ហ៊ុកអ៊ានយកទង់ជ័យចាស់ត្រឡប់ពីយាមល្បាតខាងក្រៅវិញ ឃើញបងរួមគ្រូបរាជ័យ ក៏ស្រែកព្រមគ្នា:

-ឯងបោះប្រូតគ្នាវាយបងប្អូនយើងម្នាក់. យើងក៏បោះប្រូតគ្នាវាយប្រហារឯងវិញដែរ!

ពោលចប់ ស្រែកហៅឡេងបបួលគ្នាវាំងជប់ពីរនាក់វាយសម្រុកទៅរកប្ដីប្រពន្ធស៊ីឈីង ។ ប៉ាយវ៉ាន់ជានស្មានថាអ្នកទាំងពីរប្រយុទ្ធមិនឈ្នះប្ដីប្រពន្ធគេទេ ទើបនៅរុញកម៉ិនទាន់ចូលជួយ ។ ស៊ីឈីងពោល :

- លោកបងប៉ាយ ! អម្បាញ់មិញយើងប្រូតគ្នាដល់ទៅពីរនាក់ មានប្រៀបលើបងខ្លះ តែមិនអាចថាថា លោកបងចាញ់នៅឡើយ ។ សូមអញ្ជើញសាកល្បងម្ដងទៀតមើល !

ពោលចប់លើកដាវចាក់សំដៅប៉ាយវ៉ាន់ជានភ្លាម ។ បើយោលតាមច្បាប់ពិតពគុន ប៉ាយវ៉ាន់ជានមិនត្រូវចូលរួមក្នុងការប្រយុទ្ធលើកនេះទេ ព្រោះគេលើកលែងទោសឲ្យគាត់រួចហើយ ។ ប៉ុន្តែស៊ីឈីង វាយលុកគាត់មុន ហាក់ដូចចាក់ចុចឲ្យគាត់លើកអាវុធទប់ទល់នឹងវាយតបវិញដោយបង្ខំ ។ ប៉ាយវ៉ាន់ជានទឹកថា:

- បើគេបង្ខំហៅរកហើយ ត្រូវចូលប្រយុទ្ធមួយទល់នឹងមួយម្ដងទៀតមើល ?

អម្បាញ់គាត់ត្រូវការពារខ្លួនផងវាយសងផង, បើវាយប្ដីប្រពន្ធការពារ, បើវាត់រកប្រពន្ធវិញប្ដីគេជួយរាំង ម្ល៉ោះហើយឃើញថាគាត់បញ្ចេញស្នៀតមិនបានស្រឡះដែរទេ ។ លើកនេះជាមួយទល់នឹងមួយផង, បង់លុបលាងការអាម៉ាស់មុខថ្មីៗ ផង, ប៉ាយវ៉ាន់ជានបញ្ចេញស្នៀត ដាវទាំងចិតសិបពីរប្រចាំក្រុមភ្នំទឹកកកយ៉ាងផូតផង់ ។ ពេលនេះគួចជង្នៀតគ្រាន់ ដាវប៉ាយវ៉ាន់ជានមួយក៏អាចវាយវាត់បញ្ចេញស្ទើរពេញទៅហើយ ។

ស៊ីឈីងភ្ញាក់ព្រើតលបសរសើរក្នុងពោះថា :

- នេះបានសមជាអ្នកក្លាហានវិសេសក្ដៅមែន

ចំណែកខ្លួនគាត់ក៏ចាំតាំងស្មារតីបញ្ចេញយុទ្ធសិល្បៈប្រចាំកាយ មិនឲ្យអាប់ឈ្មោះស្នៀតគុនដាវភ្នំហ៊ានសាស៊ីដែរ ។ គាត់នឹកក្នុងចិត្ត:

- យើងបញ្ជូនកូនទៅរៀនឯភ្នំទឹកកក មិនមែនបានន័យថាគុនដាវពួកឯងពូកែជាងគេនោះទេ ! បំណងយើងផ្សេងពីនេះស្រឡះហើយ ! ចូរឯងកុំប្រមាថហើយកុំស្មានថាស៊ីឈីងអន់ជាងប៉ាយវ៉ាន់ជាន ។

គូប្រយុទ្ធនេះកម្របានមើលមែន ! ដាវប៉ាយវ៉ាន់ជានមានសន្ទុះរហ័សខ្លាំងក្លៃងហោះហើរស្មើព្រាតទាំ ដាវស៊ីឈីងរលាស់មួយៗព្រឺៗដូចគីរីបព្វតា ដោះប៉ាយវ៉ាន់ជានវាយវាត់ពីខាងណាក៏យកប្រៀបមិនបានដែរ ។

អ្នកក្លាហានទិសឧត្តរក៏យំព្រួចនឹកថា:

– គុនដាវគេល្បីកហួសកេរ្តិ៍ឈ្មោះទៅទៀតហ្ន៎ ! បើអីចឹងគេបញ្ជូនកូនទៅរៀនយុទ្ធសិល្បៈពីក្រុមក្លឹកកុកធ្វើអី ? អញ្ចាញមិញយើងចាញ់គេព្រោះគេប្រួតគ្នា , ឥឡូវដៃពីរទល់នឹងពីរ បើចាញ់ទៀតអស់ផ្លូវត្រូវហើយ ។ គោងរកចំណុចណាចំហវាយលុកតែមួយស្នៀតយកជ័យមកវិញទើបលាងកេរ្តិ៍ឈ្មោះក្រុមបក្សក្លឹងពិភពគុនគទៀតបាន ។

ដោយចង់ឈ្នះដាច់ ប៉ាយវ៉ាន់ជានស្រវាវៃតែក្បាច់ ទិសរហ័សឡើង , ព្រមទាំងប្រជុំមួង ១ ផង ។

ស៊ីឈីញញឹមបញ្ចេញញឹមនឹកថា : ។

– ឯងចង់ឈ្នះដាច់ ១ ប្តូ ក្រែងទង់គេកែប្រែដាច់ចាញ់ទៅវិញទេដឹង ?

ប្រហែលដប់ស្នៀតក្រោយមកប៉ាយវ៉ាន់ជានពើបប្រទះគ្រោះថ្នាក់មែន បណ្តាលឲ្យគាត់ភ្ញាក់ក្រញ៉ាំងខំប្រមូលស្មារតីមកវិញ លែងហ៊ានវាយទាំងប្រជុំយុទ្ធប្រញាប់ទៀត ។ ពាល់តែប្រឹងប្រែងណាស់ ទើបការប្រយុទ្ធនេះបះស្មើឡើងវិញ ។

ហាណាពសម្បុរមើលទៀតដង់ក្លាំងយូរទៅរឹតតែយល់ច្រើនឡើង ព្រមទាំងយល់ចំណាំគូប្រយុទ្ធ ដូចជាប៉ាយវ៉ាន់ជានប្រជុំបង្ខំយកឈ្នះ ស៊ីឈីងទប់ទល់យ៉ាងស្ងៀមស្ងាត់មិនរលះរលាំងជាដើម ។ ការពិតគុនដាវទាំងអស់នេះមានមូលដ្ឋានតែមួយ គឺស្រ័យការហាត់រៀនរាប់សិបឆ្នាំតាមទ្រឹស្តីប្រចាំក្រុមបក្សរៀងខ្លួន ពាល់តែចេះយុទ្ធសិល្បៈ វាងវៃឆ្លាតកម្លាំងកាយសព្វគ្រប់សិនទើបមើលយល់ ។ ចំពោះបុរសអាយុម្ភៃឆ្នាំគ្រាំពីហាណាព, គ្មាននរណាមើលយល់ឡើយ, ប៉ុន្តែហាណាពជាកម្លោះមួយរូបចេះយុទ្ធសិល្បៈចាំឡេកខុសគេទាំងមិនដឹងខ្លួន ទើបមើលចេះចាំហើយយល់អស់កន្ទុកក្នុងទៀត ។ តយមើលក្លេចខ្លួន

ស៊ីឈីងទីវ ប៉ាយវ៉ាន់ជានក៏ដោតការម្នាក់លើស្នៀតដាវរៀងខ្លួន ក្មេងតិតដល់ការគេចិត្ត ថ្មឹងខ្នុំខ្ទួនអស់រលីង បានប្រហែលពីររយស្នៀតអ្នកទាំងពីរយល់ថានេះជាការហាត់ល្បងប្រចាំជីវិត

ទៅវិញ, ប៉ាយកាំងជានភ្លេចរៀងអ្នកស្រីវុនយូទាក់ទ្រូងអម្បាញ់មិញ, រីស៊ីឈីងភ្លេចគោលបំណងដណ្ដើមកូនក្រុសមួយខណៈដែរ ។ អស់ពីប្រយុទ្ធគ្នារហ័សក្លិបក្លែតនៅប្រែក្រឡាស់ជាយឺតៗ សង្កេតមើលស្នៀតគូប្រយុទ្ធរៀងខ្លួន ។ រំពេចនោះ ប៉ាយកាំងជានបញ្ចេញស្នៀត «ស្រមោលឃ្លាំងឃ្មាត» គ្រញាំងទៅមុខយ៉ាងចំឡែក ។ ស៊ីឈីងលាន់មាត់សរសើរតិចៗ :

-ស្នៀតមួយនេះល្អប្រសើរមែន !

ពោលផង បញ្ចេញដាវរងកាត់ដងក្លស្ពូវម៉ាង ! ប្រ៉ាច ! ដាវស៊ីឈីងបាក់ជាពីរកំណាត់ត្រឹម ។ ខណៈនោះ មាននរណាហុចដាវមួយទៀតឲ្យស៊ីឈីងភ្លាមៗ ម្ចាស់ក្មួយបានសារ៉ិនស៊ីវទទួលដាវរួចមកត្រឡប់វិញលំមួយផុំការពារខ្លួនទាបព្រៃងកាំងជានវាយលុកវាយ ។ ប៉ុន្តែស៊ិស្សក្លិករូបនេះដកខ្លួនទៅក្រោយពោះរមៀវម:

- ទិនមែនលោកម្ចាស់តាញ៉េ, នេះគឺមកពីដៃងាវម៉ិនសូវម៉ា ។ បើវាដាវឡោរបស់លោកខ្ញុំច្បាស់សង្ស័យមិនឡើយ ។

ពោលចប់គាត់ភ្ញាំងមុខភ្លាម ព្រោះភាគខាងណោះឃើញអ្នកស្រីវុនយូ ឈរក្រោយខ្លួនថ្លី, ប្អូនរួមគ្រូទាំងដប់ពីរនាក់ដេកគរលើគ្នាហើយពល !

ឲ្យតក្កុនៈពេលបុរសទាំងពីរដេកការប្រណាំងប្រយុទ្ធគ្នា អ្នកស្រីបានវាយស៊ិស្សទាំងបួនគ្នានសល់មួយ តែអ្នកស្រីស្លូតបូតណាស់ គ្រាន់តែចុចជីពចរម្នាក់ៗ សន្លប់ដេកប៉ុណ្ណោះ ។ អ្នកស្រីហុចដាវផ្កាលំឲ្យស្វាមី ហើយលូកដើងត្បិះដាវវិស្វក្លិកកម្មួយៈប៉ុនដល់ដៃតាប៉ាប់ដង្ហួសវិញយ៉ាងរហ័សរួចទាត់ផាយក្រោយវិញ យកដំហរសម្រាប់វាយលុកទៅទៀត ។

ប៉ាយកាំងជានខូចចិត្តបម្រើមណាស់នឹកថា :

- រូបយើងប្រយុទ្ធតទល់ នឹង ស៊ីឈីងបានត្រឹមបរស្មើ បើលោកស្រីចូលរួមផងយើងត្រូវដល់ណាទៀត ?

និកឃើញដូច្នេះគាត់ស្រែកថ្លែងៗ :

- ស្ដាយណាស់ដោយបងប្រុសរីមនុះ, បើពុំនោះសោត យើងរួមកម្លាំងពីរនាក់បងប្អូនប្រកួតសាកល្បងលោកស្រីលោកប្រុសបន្តិច ។ ពេលនេះបរាជ័យជាក់ស្ដែងហើយ, ខ្ញុំមិនត្រូវបន្ដទេ សុំអភ័យទោស ។

ស៊ីណឺនតប :

– មែន ! បើថ្ងៃក្រោយជួបបងហុង .....

គាត់ឈប់ស្ងៀមត្រឹមណោះ ព្រោះនឹកឃើញថា ហុងវ៉ាន់លីត្រូវលោកគ្រូគេកាប់ដៃបាត់ម្ខាង ដោយសាររឿងកូនប្រុសគាត់នោះហើយ មិនអាចកាន់ដាវប្រយុទ្ធ ឬ សាកល្បងទេ ។ ហេតុនេះមិនត្រូវរំឭករឿងអាស្រូវនេះទេ ។

មាណពក្រឡេកមើលមុខអ្នកទាំងបី ឃើញខុសគ្នាទាំងអស់ ។ ប៉ាយវ៉ាន់ជានមុខស្លុតស្លេក សម្លឹងទៅឆ្ងាយ ហាក់នឹករឭកដល់រឿងហេតុណាមួយគួរឈឺចាប់ , ប្តីប្រពន្ធស៊ីឈើនមុខក្រៀមស្រងូត ដូចសោកស្តាយអ្វីម៉្យាង ។ នាយពិចារណាម្នាក់ឯងថា :

-សិស្សខាងភ្នំទឹកកកទាំងដប់ពីរនាក់គ្មានបានប្រយោជន៍អ្វីសោះហ្ន៎ ! រកតែម្នាក់ចូលប្រកួតជាមួយពីរនាក់ប្តីប្រពន្ធនេះមិនបានទេឬ? មើលទៅគេបញ្ចប់ត្រឹមហ្នឹងហើយ ។

នាយនឹកដល់ខ្សែភ្នែកប៉ាយវ៉ាន់ជាន ដែលសម្លឹងនាយដោយរាប់អានក្នុងពេលមុននេះ នឹកឃើញកាលអ្នកស្រីវុនយូលូកប្រាក់ហុចឲ្យនាយនៅភូមិហ្វូវជាង នាយស្រឡាញ់រាប់អានទាំងបុរសភ្នំទឹកកកទាំងអ្នកស្រីម្ចាស់ភូមិសាំងស៊ូកឹតឹងថា :

-អ្នកទាំងបីចង់ប្រកួតសាកល្បងថ្វីដៃគ្នាទៀត តែនៅខ្វះមនុស្សម្នាក់គឺ «បងហុង» អីគេហ្នឹង មិនមកជាមួយ ។ ឥឡូវកុំឲ្យតែធ្វើមុខអឹមចឹង យើងចូលបន្ទប់សាកមើលក្រែងបានសប្បាយឡើងវិញ ។

និតហើយនាយក្រោកឈរលូកដើងផ្គិះដាវមួយតាមប៉ាយវ៉ាន់ជាន ហើយចាប់កាន់បានដូចប្រាថ្នា ទើបសើចខ្ទរ :

-អស់លោកខ្វះមនុស្សម្នាក់ ទើបលែងសប្បាយមែនទេ ? ឥឡូវខ្ញុំសុំចូលខាងលោកគ្រូប៉ាយ សាកមើលកើតឬទេ ?

ប៉ាយវ៉ាន់ជាននិងប្តីប្រពន្ធស៊ីឈើនភ្ញាក់ក្រញាំងរៀងខ្លួន ។ ប៉ាយវ៉ាន់ជានឆ្លើយ:

-យើងចុចជីពចរស៊ីផានសព្វកន្លែងទៅហើយម្តេចវ៉ាក្រោកបាន ? វុនយូភ្លេចពេលយើងជា
ដៃជាប់អារម្មណ៍ជួយស្រាយជីពចរឲ្យកូនទេដឹង ?

ចំណែកប្តីប្រពន្ធវុនយូរឆ្លើយម៉្យាងថា ប៉ាយវ៉ាន់ជានចាប់កូនប្រុសគាត់បំណាំងនាំទៅភ្នំទឹកកក ពិ
ជាចុចជីពចរយ៉ាងដំណំមិនឲ្យកំរើកខ្លួនទេ , ឥឡូវម្តេចនាយក្រោកដើរបាន ? អ្នកស្រីស្រែក

តែមួយម៉ាត់ថា «កូន !» គឺបាត់មាត់ឈរស្ងៀមស្ងឹងស្ងាម ។

ការពិតស្នៀតចុចដីពចររបស់ចៅយ៉ាក់ផានមានប្រសិទ្ធភាពណាស់ហើយមានអានុភាព ចំនួនដប់ពីរម៉ឺនយ៉ាំងតិច ។ គាត់ចុចស៊ុផកានស៊ើរគ្រប់កន្លែងឈ្មោះពេលវេលាកៀងដញ្ញាំងមែន តែនាយមានកម្លាំងក្តៅគ្រប់គ្រាន់ស្រាប់ទើបកម្លាំងនេះ ផ្សព្វផ្សាយរំលាយស្នៀតចុចដីពចរខាងក្រុមភ្នំទឹកកកដោយស្វ័យប្រវត្តិ ។ ហាណពផតជីងខ្លួនផងទេ, នាយផតជឹងគេចុចដីពចរប្រកបដោយគ្រោះថ្នាក់គឺផុចផតជឹងកម្លាំងកាយផ្ទាល់ស្រាយដីពចរបានដោយធូរដែរ ។ ចៅយ៉ាក់ផានសញ្ជឹងគិតបន្តិចទើបស្រែកសួរៈ

– ឯងចង់រួមកំឡាំងជាមួយយើងប្រយុទ្ធនេះ ក្នុងគោលបំណងយ៉ាងណា ? ចង់សាកល្បងយុទ្ធសិល្បៈខាងភ្នំទឹកកកដែលឯងផាមហាត់រៀននោះឬ ?

ផ្លកកន្ទោះនឹកដាស់ម៉ូមើលគេមួយប៉ប់ពីរប៉ប់ ហើយបេះដឹងខ្វះដែរ តែមិនដឹងធ្វើតាមគេកើតឬមិនកើត ។ នាយគោរពថ្វាំង ៗ តបវិញៈ

– ចុះខ្ញុំហាត់រេះបន្តិចបន្តួចទេ ។ សូមលោកគ្រូប៉ុយព្រមទាំងលោកប្រុសលោកស្រី ជួយកម្រែកម្រងផង ។

ក្រោយហើយនាយបើកដាវទៅឈរជិតចៅយ៉ាក់ផាន តាមស្នៀតរបស់ក្រុមភ្នំទឹកកកឈ្មោះ «ដំណើរខាងលិច» ត្រឹមត្រូវគត់គត្វោះ ។

ស៊ុឈីងនិងភរិយាផ្តោតភ្នែកសម្លឹងកូនប្រុសជានិច្ច ។ ព្រោះគាត់ឃ្លាតពីកូនយូរឆ្នាំហើយតាំងពីបញ្ជូនទៅហាត់យុទ្ធសិល្បៈនៅវិមានទឹកកក គាត់មិនដែលជួបមុខកូនម្តងណាឡើយ ។ ថ្ងៃនេះជួបកូនប្រុសដោយចៃដន្យ គាត់រីករាយផង ទឹងគ្នាន់ភ្ញាក់ផងលាយឡំគ្នា ។ មួយចំណែកទៀតគាត់ឃើញកូនប្រុសធំធាត់ស្អាតបាទចិតមុខស្រស់ថ្លា បញ្ជាក់ឲ្យឃើញភាពស្អាតបាទ, ពន្លឺភ្នែកឡៅក្រៀសមនឹងកម្លោះធ្លាកវៃ ឪពុកនិងម្តាយនឹកឃើញម៉្យាងម្នាក់ ។

ស៊ុឈីងនឹកដល់កិត្តិយស កេរ្តិ៍ឈ្មោះគ្រូមិលានសាំនស៊ូ ដែលកាប់ទុនដោយសារកូនអប្រិយផ្តាជាតិ, មិនឲ្យគាត់ចេញដើរខ្ពស់មុខក្នុងពិភពគុន ។ ប៉ុន្តែនៅថ្ងៃនេះគាត់នាំគ្នាដើរស្វែងរកកូនដោយស្ងាត់ ៗ មិនហ៊ានចេញមុខជួបអ្នកក្លាហានដទៃផង ។ ថ្ងៃនេះកូននិងឪពុកម្តាយជួបគ្នាហើយម្តេចក៏មិនចេញមកទទួល ឬ ដកបង្គួរអ្នកបានគុណ បែរជារួមកម្លាំងជាមួយគ្រូប្រយុទ្ធគ្នាទៅវិញ ?

ចំណុចតែមួយគត់នេះអាចឲ្យគាត់ថ្កោលទោសកូន , ទម្លាក់កំហុសទាំងប៉ុន្មានគាត់ ទៅ តាមអាក៏មទៅ ហើយ ។ ស៊ុយលីនក្តាប់ដៃសង្កៀតធ្មេញក្រឹត ១ តែគាត់ទំអត់ធ្មត់មិនហ៊ានដើរ ស្តីកូននៅចំពោះមុខប៉ាយភន់ផាន ។

ចំណែកវ៉ុនយុំកើបចិត្តដូចម្តាយពលរូបដែលឃ្លាតព្រាត់ពីកូនសំឡាញ់យូរឆ្នាំ ។ គាត់ក្រោយសំឡឹងតាមជំហានកូនចន់ស៊ុះទៅទុបរិតថ្នាក់ថ្នម មមិត្តនឹករព្ធក ។

ព្រោះអ្នកស្រីមានកូនប្រុសពីរនាក់, កូនប្អូនស្លាប់បាត់តាំងពីយូរដោយដៃសត្រូវធ្វើឲ្យគាត់ព្រួយចិត្តហួសប្រមាណ ទើបប្រមូលសេចក្តីស្នេហាទាំងអស់មកដាក់លើកូនច្បងឈ្មោះស៊ុផុនយីតែមួយគត់ ។ ក្នុងការដើររកកូនប្រុសនេះ គាត់ "កាន់ជើង" កូនណាស់ តែការពារកូនក្នុងការដដែកវែកញែកជាមួយស្វាម៉ីពលពេល ។ អ្នកស្រីតែងប្រកែកថា :

មិនត្រូវជឿសំដីពួកកុំមុយនិស្តទេ ព្រោះផុនយីនៅតូចមិនគួរចេះប្រព្រឹត្តអំពើជាគពាលបែបនេះឡើយ ។ ក្រែងគេធ្វើបាបពេក វាទ្រាំមិនបានលបរត់ចុះពីកុំមុយនិស្តទេដឹង ?

លុះស្វែងរកកូនប្រុសច្រើនឆ្នាំមិនជួបប្រទះសោះ អ្នកស្រីព្រួយចិត្ត លបសំរក់ទឹកភ្នែកម្នាក់ឯងជាញយ ។ បារម្ភខ្លាចកូនស្លាប់លើកុំមុយនិស្តនោះឬធ្លាក់ក្នុងចន្លោះ បត្ថា បារម្ភត្រូវផងខុចជាគណា ចាប់យកទៅធ្វើបាប ។

កាលបើឃើញមុខកូនរស់រវើកដូច្នេះ អ្នកស្រីភ្លេចទុក្ខព្រួយ ភ្លេចកំហុសកូនអស់រលីងនឹកឃើញតែម៉្យាងថាកូនប្រុសមានមុខថ្លៃកណាស់, ដំណើរសបបរាអ្នកកា ហានមានកម្លាំងស្ដុកស្តម្ភ ...

អ្នកស្រីនឹកឃើញម៉្យាងទៀតថាកូនច្បងនេះវៃឆ្លាតហើយមានគំនិតល្បិចច្រើនផង, ក្រែងវាបង្គួលប្រឡងប្រជែងតាមគោលបំណងអ្វីមួយទេដឹង ?

គាត់ខ្លាចស្វាមីដេរស្តីកូននៅមុខប៉ាយភន់ ផានតាំឲ្យកូនទឹងខូចបំណងសំខាន់ហើយចង់មើលស្នាដៃកូនដែលហាត់រៀនពីក្រុមកុំមុយនិស្តផងក៏ពោលដោយស្រទន់ :

-ល្អណាស់ ។ មក ! ពីរនាក់ចលនីវពីរកិច្ចវិភាសទុសដែរ ។

ស៊ុយលីនមើលមុខភរិយារួចងក់ក្បាលយល់ព្រម ព្រោះគាត់យល់ជំរៅចិត្តភរិយាដែលចង់ស្គាល់ពីតេជោសិល្បៈរបស់កូនប្រុសតែមួយផង ចង់ធ្វើឲ្យប៉ាយភន់ផានអស់ចិត្តផង ។ ព្រោះគាត់យល់ថាពេះផុនយីឆ្លាតវាងវៃយ៉ាងណាក៏មិនមែនគូប្រជែងដល់សិស្សក្រុមកុំមុយនិស្តទាំងអស់ពីរ ដែលវ៉ុនយុំចុះទីគោរ

ដេកដួលគរលើគ្នានោះដែរ ។

ជាពិសេសគាត់ជឿជាក់ថាកូនប្រុសមិនមែនជួយប៉ាយកង់ដានដោយស្មោះ ដើម្បីប្រឆាំងនឹងឪពុកខ្លួនទេ ។

ប៉ាយកង់ដានក៏យល់វែងឆ្ងាយ :

- បើនឹងមិនជឿថា ឯងប្រើយុទ្ធសិល្បៈប្រចាំក្នុងទឹកកកការពារក្រុមបក្សក្នុងទឹកកកទេ ។ ល្អើយ បណ្តោយឲ្យបីនាក់គេប្រះការយើងទៅ ប៉ុន្តែកុំភ្លេចថា ត្រូវសួរគ្រប់ញ្ញានាយក្រុមឲ្យស៊ីជុនយីត្រឡប់ទៅក្នុងទឹកកកទទួលទោសជាដាច់ខាត ! ប្រសិនបើស៊ីឈីងកកុំងទៀត , ពិតជាគាត់ប្រព្រឹត្តល្មើសច្បាប់ពិតពុតនហើយ ។ ចុះសព្វាហានទិសឧត្តរលើកាវុធពោលច្បាស់ ៗ :

- ពេទល់នឹងពីរក៏បាន បីទល់នឹងមួយក៏បាន ព្រោះខ្ញុំបរាជ័យដោយសារដាវមួយគូនាំក្នុមិសាទស្ងួតទៅហើយ សុខចិត្តយកជីវិតកំដរអស់លោកជាចុងក្រោយចុះ ។

គាត់ឆ្លើយបែបនេះព្រោះគាត់បានសម្រេចចិត្ត សម្លាប់ស៊ីជុនយីពាល់តែបាន ។ មាណពឃើញប៉ាយកង់ដានរុកដាវជន្លួលស៊ីឈីង ចុងភ្នែករក្រឡេកទៅឃើញស្លាប់ជាក់ជាស្បៀតវាយលុកផងការពារខ្លួនផងក៏ស្រែកគាត់:

-ទុកខ្ញុំវាយលុកមុន ។

ពេលចប់លោះដាវពាក់តម្រង់ស្មាស៊ីឈីងវិប !

មាណពមិនហ៊ានហួនចុំគ្មានទៀយ ព្រោះមិនដែលសាកល្បងប្រយុទ្ធជាមួយនរណាសោះ ប៉ុន្តែកម្លាំងធាតុនាយស្ដុកស្ដម្ភណាស់, ចាំងធាតុក្តៅធាតុត្រជាក់ វិញចញ្ចូលគ្នាធ្វើគាត់ផ្ទៃដាវត្រឡប់ទៅឡើយ ១ គួរព្រឺខ្លួន ។ នេះជាស្បៀតដាវក្នុងទឹកកកសុទ្ធសាធដែលប៉ាយកង់ដានធ្លាប់ប្រើ តែប្រើមិនបានដូចមាណពព្រោះគាត់មានកម្លាំងតិចជាងនាយ ។ គ្រាន់តែមាណពបញ្ចេញមួយស្បៀតជំនួស , ស៊ីឈីងនិងវុនយូលាន់មាត់យ៉ើ ! ដំណាលគ្នា ។ ប៉ាយកង់ដានពេបជ្រាយក្នុងពោះថា :

- ឯងប្រើស្បៀត« ពពកកាត់ភ្នំ » នេះមិនត្រូវទេ ។ មើលចុះ លើកដៃខ្ពស់ពេកវាយគេម្ដេចត្រូវ ? ដៃឆ្វេងក៏ដាក់ឥតត្រូវទៀត, ជើងឆ្វេងបោះទៅមុខឆ្ងាយជ្រុលបើសត្រូវវាយសងវិញជើងឯងពិតជារបួសមិនខាន ។

ប៉ាយកង់ដានក្រឡេកភ្វាប់ឃើញកំហុសច្រើនកន្លែងតែមួយរំពេចនោះ គាត់ស្រឡាំងកាំងភ្លាមព្រោះ

បន្ទះ ដាវមាណពដក់ខ្យល់ឲ្យសម្ងួនខ្លាំងក្រៃលែងសឹងមិនជឿត្រចៀក ។ ឪពុកគាត់ជានាយក្រុមកុំទិកកកធ្លាប់បញ្ចេញថ្វីដៃបង្ហាញសិស្សម្តង១ក្នុង៤ការស្រវឹងស្រាអាចបញ្ចេញសន្ទុះដាវលាន់ឈិបៗ ឈិប ! ដូច្នេះដែរ, តែគាត់ត្រូវបញ្ចេញជល់ខ្លួនសាមសិបឬសែសិបស្នៀតមុន ដើម្បីប្រមូលកម្លាំងសិន ។

ស៊ីផានបញ្ចេញស្នៀតដំបូងសោះ ម្តេចក៏លាន់សន្ធឹកខ្លាំងម្ល៉េះ ? គេមានចងកណ្តឹងនៅចុងការុធឬ ? ទេ ... កុំរវើរវាយ ...

ខណៈដែលប្តីប្រពន្ធលាន់មាត់យី ! នោះគេឮសូរធ្ងន់ដំណាលគ្នា គឺផ្លែដាវស៊ីឈីនបាក់ជាពីរកំណាត់ប៉ុនមួយកន្លះទៅប៉ះជញ្ជាំងលាន់ពិប ! ស៊ីឈីនញ័រដៃទទ្រើកកាន់ដងដាវស្ទើរមិនជាប់ ។ ប៉ុន្តែក្នុងឋានៈជាអ្នកគុននិយមគាត់ត្រូវសរសើរថា « ល្អ » មួយម៉ាត់ កាលបើជួបប្រទះអ្នកខ្លាំងពូកែជាងខ្លួន ទោះអ្នកនោះជាកូនបង្កើត , ជាកូនអកតញ្ញូក៏ដោយ ។

ស៊ីឈីនទឹងក្រោធក្រហមមុខ, ស៊ីផានឃើញដាវគាត់បាក់ជាពីរនាយភ្ញាក់ព្រើតលាន់មាត់អូ ដោយស្តាយនិងតក់ស្លុត ។ ពេលនេះមាណពបែរមុខចំពន្លឺទៀនអាចបង្ហាញទឹកចិត្តឲ្យស៊ីឈីននិងវុនយូមើលច្បាស់ណាស់ ។ គេនឹកអរកើតដំណាលគ្នា ថាកូនយើងមិនមែនអកតញ្ញូឯណា ? វាបេះស្តាយបេះអាណិតម៉ែឪដែរទេតើ !

ស៊ីឈីន គ្រវាត់ដាវកំបាក់ចោលហើយលូកដើរឆ្កឹះដាវមួយទៀតមកកាន់រួចពោលៈ

— កុំក្រែងវែងអី, ចូលមកទៀតចុះ ។

ពេលចប់យារដាវតាក់ជើងធ្វេងមាណពភ្លាម ។ ស៊ីផានមិនដែលហាត់រៀនសិល្បៈគុនដាវសោះមកជួបស្នៀតវិសេសខាងក្បួនហានសាមស៊ូក៏លេះលោងមិនដឹង វាយសងវិញយ៉ាងដូចម្តេចព្រោះនាយឥតបានមើលស្នៀតប្តីប្រពន្ធស៊ីឈីនអស់សព្វគ្រប់ទេ ។ ប៉ុន្តែទឹកជល់ប្រមុះហើយនាយលើកដាវវង់កាត់តាំងទទឹងទិសបណ្តោយឲ្យស៊ីឈីនផ្លៀងការុធរុកជល់ជើងស្តាំនាយភ្លាម ។ បើគាត់មិនយោគយល់ថាមាណពជាកូនបង្កើតទេនោះ ស៊ីឈីនអាចប្រើតែមួយស្នៀតគត់កាប់ជើងនាយបាក់ជាពីរបីកំណាត់ភ្លាម ។ គាត់ក៏រើកដៃអង្រួនដាវធ្វើឲ្យវុនយូភ័យស្ទុះស្រែកឃាត់ៈ

— បងឈីន ! . . .

មាណពភ្ញាក់ព្រើតឱនមើលជើងស្តាំឃើញដាច់ហែកកំណាត់ខោមួយកន្ទៃ តែឥតរបួសជល់

សាច់ទៀយ ។ នាយពោលដោយត្រេកអរ:

– សូមអរគុណលោកដែលមិនសម្លាប់ខ្ញុំ ។ គុនជាវលោកពូកែលើសខ្ញុំឆ្ងាយណាស់ ។

កថានេះហូរចេញពីទឹកចិត្តដ៏ស្មោះត្រង់ពិតៗ តែអ្នកស្តាប់យល់ឃើញផ្សេងទៅវិញ ។ ប៉ាយវ៉ា

ជានឥតពេញចិត្តពាល់តែសោះ ដោយនឹកថា:

–ឯងសរសើរឪពុកម្តាយដូចជាវ៉ាយក្បាលយើងអីចឹង ។ ហ៊ឺះ! ឪពុកឯងបេះគុនជាវខ្លាំងពូកែ

លើសក្រុមក្ដិចកកកផងឬ ? តាឯងមានកលល្បិចបេ៉ុនណាស់ លើកតំកល់ឪពុកឯងសិនចុះ, តែសូម

ភ្លេចថាដកបណា ប៉ាយវ៉ាន់ជានទៅមានដង្ហើម,ឯងមិនអាចហាមាត់ក្នុះក្និះជៀលក្រុមក្ដិចកកកបានទេ ។

ចំណែកសឺឈីងគាត់ជ្រួញចិញ្ចើមនឹកថា:

- អូនយូបេះតែអះអាងថាកូន ទៅហាត់រៀនឯក្ដិចកកក ត្រូវចង្អុរួមត្រូវធ្វើបាប ។ តា

យើងស្មានលោកអីប៉ាយក្តិចង ហ្វុងក្តីសុខតែជាអ្នកក្លាហានស្មោះត្រង់ណាស់ ។ កាលបើចូ

កូនយើងជាសិស្សហើយគេមិនហ៊ានធ្វើបាបវ៉ាទេ ។ ប៉ុន្តែគួរឆ្ងល់ណាស់, មើលកាយវិកា

ដូចជាមិនច្បាស់លាស់សោះ, រៀនបៀបហ៊ឹង គាពោះខុនម្ដេចបាន ? មើលទៅវ៉ាឥតបា

ហាត់រៀនប៉ុន្មានទេ, កម្លាំងតាគុវ៉ាក៏ឥតខាងចង់នឹងក្រុមក្ដិចកកកដែរ, លោកគ្រូធំជានាយក្រុ

ប្រហែលគ្មានកម្លាំងកាយស្ដុកស្ដម្ភដល់វ៉ាទេ ។ ប្រហែលកូនយើនេះមានភ័ព្វវាសនាបានជួបអ្ន

ខ្លាំងពូកែរូបណាទេដឹង ? គួរតែកញ្ចែករឿងនេះឲ្យច្បាស់លាស់ដែរទើបថ្ងៃក្រោយស្រួលដែកគ្នា

ដោយហេតុខាងលើនេះ បានជាគាត់ពោល :

– មក! មក! កុំរុញរកអី, ចូលមកប្រកួតគ្នាឲ្យបានជឿនលឿន ។

ពោលហើយលាដៃឆ្វេងរុញដាវតាក់ប៉ាយវ៉ាន់ជាមមុន ។ ប៉ាយវ៉ាន់ជានលើកដាវទង់វិ

ដ៏ប្រញាប់ :

នៅខាងណោះវុនយូលើកតាវុងតាក់កូនប្រុសមួយៗ ខ្លាបកូនភ័យរលះរលាំងរកស្មៀតវ៉

សងវិញមិនទាន់ ។ ស៊ុំផងានឃើញអ្នកស្រីថ្នមដៃនាយ នឹកដល់ពេលអ្នកស្រីហុចប្រាក់ឲ្យនាយ

នៅភូមិហ្វូវជាន , នាយសើចញញឹមងក់ក្បាលថ្លែងសេចក្តីអរគុណរួច ទើបលើកដាវវង់កាត់

(នៅមានត)

ដំកល់ទុកតាមលេខ ៣១០ ចុះថ្ងៃទី ២២ ៩-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers